**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

**មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍**
**សើស្បែកនិងកាមរោគ**

## របាយការណ៍ស្តីពី

## សកម្មភាពការអប់រំផ្សព្វផ្សាយ និងធ្វើតេស្តរកមេរោគអេដស៍ និងមេរោគស្វាយ ក្នុងព្រឹត្តិការណ៍នៃព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក របស់ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

**សកម្មភាពរយៈពេល ៤ថ្ងៃ គឺចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៤**

ដោយទទួលបានការណែនាំ និងចង្អុលបង្ហាញដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមសាស្ត្រាចារ្យ ឈាង រ៉ា** រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងក្រោមការដឹកនាំដោយផ្ទាល់ដោយ **ឯកឧត្តមវេជ្ជបណ្ឌិត ស៊ឹម ស៊ូយេង** អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល **ឯកឧត្តមវេជ្ជបណ្ឌិត មាន ឈីវុន** ទីប្រឹក្សាក្រសួងសុខាភិបាល និង **លោកសាស្ត្រាចារ្យជំនួយ អ៊ុក វិជ្ជា** ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ បានដឹកនាំសកម្មភាពផ្ទាល់រយៈពេល ៤ថ្ងៃ គឺចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៤ ជាមួយក្រុមការងារមន្ត្រីជំនាញមជ្ឈមណ្ឌលជាតិ និងអង្គការដៃគូពាក់ព័ន្ធសម្រាប់ការរៀបចំយុទ្ធនាការផ្សព្វផ្សាយអប់រំការយល់ដឹងស្តីពីការបង្ការមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាមរោគ និងការចុះចែកស្រោមអនាម័យដោយឥតគិតថ្លៃដល់កីឡាករអុំទូក និងដល់សាធារណជនដែលចូលរួមនៅក្នុងឱកាស ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក នៅតំបន់ទីក្រុងរណបជ្រោយចង្វារ (OCIC)។

### យុទ្ធនាការផ្សព្វផ្សាយអប់រំការយល់ដឹងស្តីពីការបង្ការមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាមរោគ

ក្រុមការងារបានរៀបចំឱ្យមានការហែរដើរក្បួនដែលដឹកនាំដោយ **ឯកឧត្តមវេជ្ជបណ្ឌិត ស៊ឹម ស៊ូយេង** អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល **ឯកឧត្តមវេជ្ជបណ្ឌិត មាន ឈីវុន** ទីប្រឹក្សាក្រសួងសុខាភិបាល និង **លោកសាស្ត្រាចារ្យជំនួយ អ៊ុក វិជ្ជា** ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ដែលមានកាន់បដា និងរូបភាពផ្សព្វផ្សាយទាក់ទាញផ្សេងៗ ស្រោមអនាម័យ ព្រមទាំងមានការចូលរួមផងពីសំណាក់ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ តំណាង

មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានីភ្នំពេញ អង្គការដៃគូ រួមមានអង្គការ AHF, FHI 360, KHANA, PSI, MHC, CWPD និងសមាគមឈូកស សរុបចំនួន ១២០ នាក់។

នាល្ងាចថ្ងៃដដែលនោះផងដែរ ក្នុងឱកាសយុទ្ធនាការនោះផងដែរ **ឯកឧត្តមសាស្ត្រាចារ្យ ឈាង រ៉ា** រដ្ឋមន្ត្រីក្រសួងសុខាភិបាល អមដំណើរដោយ ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំក្រសួងសុខាភិបាល បានអញ្ជើញចុះពិនិត្យការរៀបចំទីតាំងជម្រកតង់សុខភាពក្រុមគ្រូពេទ្យយាមប្រចាំការ និងរថយន្តគិលានសង្គ្រោះនៅតាមបណ្តាគោលដៅនីមួយៗ ដើម្បីចូលរួមការពារ ពិនិត្យព្យាបាលសុខភាពជូនប្រជាពលរដ្ឋ ដែលអញ្ជើញមកចូលរួមទស្សនាក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក និងស្តង់ផ្សព្វផ្សាយអប់រំការយល់ដឹងស្តីពីការបង្ការមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាមរោគរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ។





សកម្មភាពអប់រំផ្សព្វផ្សាយ និងធ្វើតេស្តរកមេរោគអេដស៍ និងមេរោគស្វាយ ក្នុងព្រឹត្តិការណ៍នៃព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក

➢ **សមាសភាពក្រុមការងារសរុបសម្រាប់រយៈពេល ៤ថ្ងៃ នៅស្តង់អប់រំផ្សព្វផ្សាយ និងធ្វើតេស្តរកមេរោគអេដស៍ និងមេរោគស្វាយ នៅតំបន់ទីក្រុងរណបជ្រោយចង្វារ(OCIC)៖**

- ក្រសួងសុខាភិបាល ០២ រូប
- មន្ត្រីមជ្ឈមណ្ឌលជាតិចំនួន ៨៥ រូប
- ក្រុមការងារ AHF ១០ រូប
- ក្រុមការងារ FHI360 ០៣ រូប
- ក្រុមការងារ PSI ០៤ រូប
- ក្រុមការងារ KHANA ០៣ រូប
- ក្រុមការងារ MHC ១០ រូប
- ក្រុមការងារ CWPD ១២ រូប
- ក្រុមការងារ Chhouk Sar ០២ រូប
- ក្រុមការងារកម្មវិធីអេដស៍មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានីភ្នំពេញ ០៣ រូប




➢ **សកម្មភាព៖**

ក្រុមការងារដឹកនាំដោយមជ្ឈមណ្ឌលជាតិ បានសហការយ៉ាងជិតស្និទ្ធិ និងមានការចូលរួមយ៉ាងសកម្មអស់ពីកម្លាំងកាយចិត្ត ពីសំណាក់ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកនៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ តំណាងមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានីភ្នំពេញ អង្គការដៃគូរួមមាន អង្គការ AHF, FHI360, KHANA, PSI, MHC, CWPD សមាគមឈូកស និងតំណាងក្រុមប្រជាជនគន្លឹះ ក្នុងសកម្មភាពជង្ហែរជា

ក្រុមដែលមានអ្នកចូលរួមចំនួន ១២០ នាក់ ចុះអប់រំផ្សព្វផ្សាយនៅតាមដងផ្លូវ និងកន្លែងស្នាក់នៅរបស់កីឡាករ អុំទូក ដើម្បីអប់រំលើកកម្ពស់ការយល់ដឹងអំពីការប្រើប្រាស់ស្រោមអនាម័យ ការប្រើប្រាស់ថ្នាំប្រិព ផ្តល់សេវាធ្វើតេស្ត រកមេរោគអេដស៍ផ្អែកតាមគោលការណ៍ស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ ព្រមទាំងផ្តល់សម្ភារអប់រំ ស្រោមអនាម័យ ទឹករំអិល ថ្នាំព្រឹព និងការព្យាបាលដោយឱសថប្រឆាំងមេរោគ អេដស៍ដល់អ្នកចូលរួមទស្សនាស្តង់ទាំង ៥កន្លែង ក្នុងគោលបំណងចូលរួមទប់ស្កាត់ការឆ្លងរាលដាលនៃមេរោគ អេដស៍ចៀសវាងការនាំមេរោគអេដស៍ទៅចម្លងគ្រួសារ និងសហគមន៍ លើកកម្ពស់សុខភាព និងសុខមាលភាពជូនប្រជាពលរដ្ឋ ដែលអញ្ជើញមកចូលរួមក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ។ ក្នុងពេលនោះដែរ ក្រុមការងារ បានត្រៀមនូវសម្ភារ បរិក្ខារ និងខិត្តប័ណ្ណអប់រំផ្សព្វផ្សាយសម្រាប់សកម្មភាពនៃការអប់រំផ្សព្វផ្សាយពីមេរោគ អេដស៍ ជំងឺអេដស៍ និងជំងឺកាមរោគក្នុងព្រឹត្តិការណ៍នេះនូវស្រោមអនាម័យ ចំនួន ១១៥ ២០០ ស្រោម ទឹករំអិល ចំនួន ៤ ០០០ កញ្ចប់ ខិត្តប័ណ្ណផ្សព្វផ្សាយអំពីការការពារ និងធ្វើតេស្តឈាមចំនួន ៤៥ ៥០០សន្លឹក អាវយឺត ចំនួន ១១៥០ អាវ ថ្នាំបង្ការមុន-ក្រោយពេលប្រឈម (PrEP&PEP) ចំនួន ១០០ឈុត និងតេស្តរកមេរោគអេដស៍ និងកាមរោគ។

លើសពីនេះទៅទៀតក្រុមការងារបានមានមតិសំណេះសំណាល និងបានធ្វើការអប់រំផ្សព្វផ្សាយស្តីពីមេរោគ អេដស៍ ជំងឺអេដស៍ ជំងឺកាមរោគ និងការបង្ការផ្សេងៗដោយក្រុមការងារពេលដង្ហែក្បួនទៅកាន់បងប្អូនជាកីឡាករអុំទូក ប្រមាណជាង ៦០០ នាក់ ដែលកំពុងមានវត្តមាន តាមដងផ្លូវ និងនៅតាមកន្លែងស្នាក់នៅ ដោយមានការសម្របសម្រួលពិសេសជាមួយប្រធានក្រុមរបស់កីឡាករអុំទូក ក្នុងការបញ្ជ្រាបការយល់ដឹង ស្តីពីការបង្ការមេរោគ អេដស៍ ជំងឺអេដស៍ និងជំងឺកាមរោគ។




ក្នុងនោះផងដែរថ្នាក់ដឹកនាំ និងក្រុមការងារបានធ្វើបទសម្ភាសន៍ជាមួយស្ថានីយ៍ទូរទស្សន៍បាយ័ន(BTV) Fresh news និងក្រុមសារព័ត៌មានបានចុះយកព័ត៌មាននិងចុះផ្សាយនូវសកម្មភាព នៃយុទ្ធនាការនេះផងដែលដើម្បីចូលរួមចំណែកបន្ថែម ក្នុងការពង្រីកការផ្សព្វផ្សាយខ្លឹមសារអប់រំ ក្នុងអំឡុងព្រឹត្តិការណ៍នេះ។

ក្នុងថ្ងៃនីមួយៗនៃសកម្មភាពនេះក្រុមការងារបានធ្វើការបែងចែកវេនគ្នា និងបំបែកជាក្រុមតូចៗ ដើម្បីចុះអប់រំដល់កន្លែងកីឡាករអុំទូកស្នាក់នៅ ចែកខិត្តប័ណ្ណអប់រំ ស្រោមអនាម័យ សំនួរចម្លើយពីបញ្ហាអេដស៍ ផ្តល់ការប្រឹក្សាធ្វើតេស្តរកមេរោគអេដស៍-ស្វាយដល់អ្នកស្ម័គ្រចិត្តដែលចង់ដឹងពីស្ថានភាពរបស់ខ្លួន។



ក្នុងសកម្មភាពចុះអប់រំផ្សព្វផ្សាយនាពេលនេះ មានការពិតចិត្ត និងចូលរួមពីសំណាក់ កីឡាករអុំទូក ប្រជាពលរដ្ឋដែលអញ្ជើញចូលរួម ក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក យ៉ាងច្រើនកុះករ និងទទួលបានលទ្ធផលជាទីមោទនភាពក្នុងការចូលរួមបង្ការ ទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ដើម្បីជំរុញឱ្យសម្រេចគោលដៅលុបបំបាត់ការចម្លងមេរោគអេដស៍ថ្មី ស្របតាមគោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍ សម្រាប់ឆ្នាំ២០២៣-២០២៨។



លើសពីនេះផងដែល ក្នុងអំឡុងព្រឹត្តិការណ៍នេះក្រុមការងារបានរៀបចំស្លាយខ្នាតធំ ដើម្បីដាក់បង្ហាញនូវវីដេអូអប់រំផ្សព្វផ្សាយនានា ដល់សាធារណជន ជាពិសេសបងប្អូនជាកីឡាករអុំទូកស្នាក់នៅទីនោះ ក្រុមការងារបានបន្តចែកខិត្តប័ណ្ណអប់រំ ស្រោមអនាម័យ សំនួរចម្លើយពីបញ្ហាអេដស៍ និងកាមរោគ ផ្តល់ការប្រឹក្សាធ្វើតេស្តរកមេរោគអេដស៍-ស្វាយ ដល់អ្នកស្ម័គ្រចិត្តដែលចង់ដឹងពីស្ថានភាពរបស់ខ្លួន។

ក្នុងយុទ្ធនាការនេះបានទទួលនូវលទ្ធផលផ្លែផ្កាគួរជាទីគាប់ចិត្ត ស្ថិតក្រោមកិច្ចសហការណ៍យ៉ាងជិតស្និតពីសំណាក់ក្រុមការងារមជ្ឈមណ្ឌលជាតិ តំណាងមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានីភ្នំពេញ និងអង្គការដៃគូទាំង

អស់មកចូលរួមដើម្បីពង្រីកសារនៃការអប់រំទាំងនេះគ្រប់ទីកន្លែងមានបងប្អូនប្រជាពលរដ្ឋ ជាពិសេសកីឡាករអុំទូក ក្នុងការបញ្ជ្រាបការយល់ដឹងស្តីពីការបង្ការមេរោគអេដស៍ ជំងឺអេដស៍ ជំងឺកាមរោគ និងដាស់តឿនក្រើនរំឭកដល់កីឡាករអុំទូក និងបងប្អូនជនរួមជាតិទាំងអស់ សូមឱ្យប្រុងប្រយ័ត្នបង្ការខ្លួនជាប់ជានិច្ចកុំឱ្យឆ្លងមេរោគអេដស៍ព្រោះជំងឺអេដស៍ និងសុំឱ្យប្រើប្រាស់ស្រោមអនាម័យឱ្យបាន១០០% នៅពេលមានដៃគូក្រៅ និងប្រញាប់ទៅធ្វើតេស្តរកមេរោគអេដស៍ប្រសិនបើសង្ស័យថាមានផ្ទុកមេរោគអេដស៍ ដើម្បីឆាប់បានទៅទទួលសេវាផ្តល់ប្រឹក្សាធ្វើតេស្ត និងទទួលឱសថពន្យារជីវិតអោយបានកាន់តែឆាប់រហ័សក្នុងថ្ងៃតែមួយ។





# សមិទ្ធផលសង្ខេបរួម ថ្ងៃទី១៣ ដល់ ១៦ ខែ វិច្ឆិកា ឆ្នាំ ២០២៤

| ល.រ | សកម្មភាព | ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០២៤ | ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០២៤ | ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០២៤ | ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០២៤ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១ | បានអប់រំផ្សព្វផ្សាយ | 11,479 | 14,700 | 6,480 | 9,820 | **42,479** |
| ២ | បានធ្វើតេស្តឈាម | 12 *(Female: 5)* | 31 *(Female: 2)* | 27 *(Female: 0)* | 5 *(Female: 0)* | **75** *(Female: 7)* |
| ៣ | លទ្ធផលអេដស៍តេស្តប្រតិកម្ម | **00** | **00** | **00** | **01** | **01** |
| ៤ | លទ្ធផលស្វាយតេស្តប្រតិកម្ម | **00** | **00** | **00** | **01** | **01** |
| ៥ | បានចែកស្រោមអនាម័យ | 34,419 | 44,322 | 19,728 | 29,572 | **128,041** |
| ៦ | បានចែកទឹករំអិល | 1,000 | 2,613 | 3,000 | 1,100 | **7,713** |
| ៧ | បានចែកខិត្តប័ណ្ណ | 11,479 | 8,920 | 2,860 | 6,900 | **30,159** |
| ៨ | បានចុះឈ្មោះសេវា PrEP | 01 | 00 | 00 | 00 | **01** |
| ៩ | បានចុះឈ្មោះសេវា PEP | 00 | 00 | 02 | 03 | **05** |
| ១០ | អាវយឺតសម្រាប់អប់រំ | 600 | 400 | 100 | 50 | **1,150** |

ថ្ងៃចន្ទ ៣រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ ២០២៤

| បានឃើញ និងឯកភាព | បានពិនិត្យត្រឹមត្រូវ | ត្រួតពិនិត្យដោយ | អ្នកធ្វើរបាយការណ៍ |
|---|---|---|---|
| **ប្រធានមជ្ឈមណ្ឌលជាតិ** | អនុប្រធានមជ្ឈមណ្ឌលជាតិ | ប្រធានការិយាល័យរដ្ឋបាល | |
| សាស្ត្រាចារ្យ ជ.**អ៊ុក វិជ្ជា** | **វេជ្ជ. ខ៊ុំ បូរ៉ា** | **វេជ្ជ. កយ សុខា** | **ចំរើន បូរ៉ា** |

( សូមភ្ជាប់មកជាមួយរូបភាពសកម្មភាពដូចខាងក្រោម )



សកម្មភាពអប់រំផ្សព្វផ្សាយ និងធ្វើតេស្តរកមេរោគអេដស៍ និងមេរោគស្វាយ ក្នុងព្រឹត្តិការណ៍នៃព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក










សកម្មភាពអប់រំផ្សព្វផ្សាយ និងធ្វើតេស្តរកមេរោគអេដស៍ និងមេរោគស្វាយ ក្នុងព្រឹត្តិការណ៍នៃព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក


















សកម្មភាពអប់រំផ្សព្វផ្សាយ និងធ្វើតេស្តរកមេរោគអេដស៍ និងមេរោគស្វាយ ក្នុងព្រឹត្តិការណ៍នៃព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក






សកម្មភាពអប់រំផ្សព្វផ្សាយ និងធ្វើតេស្តរកមេរោគអេដស៍ និងមេរោគស្វាយ ក្នុងព្រឹត្តិការណ៍នៃព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក